# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*****

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

លេខ: ២៤/២២-PPSEZ

# សេចក្តីជូនដំណឹង

## ស្តីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក របស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក កាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតទាំងអស់មេត្តាជ្រាបថា ដោយអនុលោមតាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាលទាំងអស់កាលពីនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០២២ ។ ដូច្នេះការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនេះមានការកំណត់ដូចខាងក្រោម:

១. កាលបរិច្ឆេទកំណត់ទុក (Recorded date): ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២២

២. កាលបរិច្ឆេទកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក: ថ្ងៃព្រហស្បតិ៍ ទី ២៨ ខែ មេសា ឆ្នាំ ២០២២

៣. ទីកន្លែង: សណ្ឋាគារខេមបូឌីយ៉ាណា

៤. របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក:

| | |
|---|---|
| ៩:០០ | ការចុះឈ្មោះចូលរួមរបស់ម្ចាស់ភាគហ៊ុន |
| ៩:៣០ | ការណែនាំសមាជិកក្រុមប្រឹក្សាភិបាល |
| ៩:៣៥ | សន្ទរកថាបើកកិច្ចប្រជុំដោយអ្នកឧកញ៉ា គិត ម៉េង ប្រធានក្រុមប្រឹក្សាភិបាល នៃ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី |
| ៩:៤៥ | ប្រកាសពីរបៀបវារៈនៃកិច្ចប្រជុំ និងបទបង្ហាញអំពីដំណើរការនៃការបោះឆ្នោត |
| ៩:៥៥ | បទបង្ហាញនៃសេចក្តីសម្រេចទី១: អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១ |
| ១០:០៥ | បទបង្ហាញនៃសេចក្តីសម្រេចទី២: ការបោះឆ្នោត និងតែងតាំងក្រុមប្រឹក្សាភិបាលសម្រាប់អណត្តិថ្មី |
| ១០:១០ | បទបង្ហាញនៃសេចក្តីសម្រេចទី៣: អនុម័តកំណត់ហេតុនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ ២០២១ |
| ១០:១៥ | បទបង្ហាញនៃសេចក្តីសម្រេចទី៤: អនុម័តការតែងតាំងសវនករខាងក្រៅ (ដើម្បីបន្តសវនកម្មបន្ទាប់) |

**PHNOM PENH SEZ PLC.**
National Road No.4, Sangkat Kantuk, Khan Kambol, Phnom Penh, Cambodia.
+855 (0)23 729 798 sales@ppsez.com
www.ppsez.com

| | |
|---|---|
| ១០:២០ | បទបង្ហាញនៃសេចក្តីសម្រេចទី៥: អនុម័តការបន្តសិទ្ធិសម្រាប់ការទិញភាគហ៊ុនត្រឡប់មកវិញ |
| ១០:២៥ | បទបង្ហាញនៃសេចក្តីសម្រេចពិសេស ដើម្បីស្នើសុំការផ្លាស់ប្តូរឈ្មោះក្រុមហ៊ុនពី ភ្នំពេញ អេសអ៊ីហ្ស៊េត ភីអិលស៊ី ទៅជា រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្ស៊េត ភីអិលស៊ី។ |
| ១០:៣៥ | សំណួរ និងចម្លើយ |
| ១០:៤៥ | ប្រមូលសម្លេងឆ្នោត |
| ១០:៥៥ | សម្រាក និងអាហារសម្រន់ |
| ១១:១០ | បទបង្ហាញអំពីផែនការអាជីវកម្មនិងទិសដៅយុទ្ធសាស្ត្រនៃឆ្នាំសារពើពន្ធ ២០២២ |
| ១១:២៥ | ប្រកាសលទ្ធផលនៃការបោះឆ្នោត |
| ១១:៣០ | បញ្ចប់កិច្ចប្រជុំ |

ម្ចាស់ភាគហ៊ុនដែលនៅបរទេសមិនអាចចូលរួមក្នុងការប្រជុំបាន អាចមានតំណាងដល់នរណាម្នាក់ ដើម្បីចូលរួម និងបោះឆ្នោតលើសេចក្តីសម្រេច (ប្រសិនបើមាន) ក៏ដូចជាយើងនឹងចែករំលែកប្រព័ន្ធនៃការហៅជាវីដេអូទៅកាន់ពួកគេ។

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២២ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិក ឬការខលហៅពីក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី (ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់) ឬអាចទទួលបានលិខិតអញ្ជើញនៅទីស្នាក់ការរបស់ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី ដែលមានអាសយដ្ឋាន លេខ ៨៧B ឧកញ៉ា ជ្រុនយូហាក់ (ផ្លូវលេខ២៩៤) សង្កាត់បឹងកេងកង ខណ្ឌ ចំការមន រាជធានីភ្នំពេញ រៀងរាល់ ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី ១១ ខែ មេសា ២០២២ ដល់ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២២ ។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកមេត្តាបញ្ជាក់ពីការចូលរួមទៅឲ្យក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវ អត្តសញ្ញាណវិនិយោគិន និងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ចាប់ពី ថ្ងៃទី ១៩ ខែ មេសា ២០២២ ដល់ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២២។

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

បញ្ជាក់: ភាគហ៊ុនិកដែលអញ្ជើញមកចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក សូមភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់ជូន ដើម្បីចុះវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិករបស់ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម:

ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី

| | | |
|---|---|---|
| អាសយដ្ឋាន | ៖ | លេខ៨៧B ឧកញ៉ាក្រូចឆ្មារយូហាក់ (ផ្លូវលេខ២៩៤) សង្កាត់ បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ទូរស័ព្ទលេខ | ៖ | (៨៥៥) ២៣ ៩៨៧ ១០០ |
| ទូរសារលេខ | ៖ | (៨៥៥) ០១៥ ៨៨៨ ២៣៣ |
| អ៊ីម៉ែល | ៖ | info@tricoracambodia.com |
| គេហទំព័រ | ៖ | www.tricorcambodia.com |

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២២

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី PHNOM PENH SEZ PLC. KINGDOM OF CAMBODIA